ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈ:កម្មាធិការជាតិរៀបចំការបោះឆ្នោត
លេខ: ៦០៩ គ.ជ.ប

មុខតំណែង និងលក្ខខណ្ឌដែលត្រូវ
ជ្រើសរើសមន្ត្រីជាប់កិច្ចសន្យារយៈពេលខ្លីនៅឱ្យកដ្ឋានរដ្ឋបាល

I-**មុខតំណែង**

១- មន្ត្រីទទួលការងារបុគ្គលិក	: ២ នាក់
២- មន្ត្រីទទួលការងារបៀវត្ស	: ២ នាក់
៣- មន្ត្រីពិធីការ	: ២ នាក់
៤- មន្ត្រីបណ្ណាល័យ	: ៣ នាក់
៥- មន្ត្រីគ្រប់គ្រងទឹកភ្លើង ទូរស័ព្ទ និងឧបករណ៍បំពងសម្លេង	: ៤ នាក់
៦- លេខាធិការ	: ១ នាក់
៧- លេខហារី	: ១ នាក់
៨- អ្នកយាម (សន្តិសុខ)	: ២ នាក់
៩- អ្នកសំអាត	: ៤ នាក់
សរុប :	**២១ នាក់**

II- **លក្ខខណ្ឌទូទៅសម្រាប់ជ្រើសរើស** ÷

- មានសញ្ជាតិខ្មែរ និងមានអាយុតាមការកំណត់ក្នុងលក្ខខណ្ឌដោយឡែក
- មានចរិតស្មោះត្រង់ និងសុចរិតទៀងត្រង់ គោរពច្បាប់
- មានឆន្ទៈបម្រើការងារក្នុងជំហរអព្យាក្រឹត និងមិនលំអៀង
- មិនមែនជាមន្ត្រីតុលាការក្នុងក្របខ័ណ្ឌការងារ
- មិនមែនជាព្រះសង្ឃ ឬបព្វជិតសាសនា
- មិនមែនជាជនដែលតុលាការផ្តន្ទាទោស ដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ហើយដែលមិនទាន់មាននីតិសម្បទាឡើងវិញ
- មានសញ្ញាបត្របញ្ជាក់អំពីការសិក្សា ឬ បទពិសោធន៍សមមូល
- មានសុខភាពល្អ និងលទ្ធភាពធ្វើដំណើរទៅទូទាំងព្រះរាជាណាចក្រកម្ពុជា
- មានវត្តមានពេញម៉ោងក្នុងពេលធ្វើការ
- ប្រសិនបើបេក្ខជនជាមន្ត្រីរាជការក្នុងស្ថាប័នណាមួយ ត្រូវដាក់ពាក្យសុំឈប់ពីស្នែងពីស្ថាប័នដើមក្រោយពី គ.ជ.ប ចេញសេចក្តីសម្រេចតែងតាំង
- បេក្ខជនអាចដាក់ពាក្យបានតែមួយមុខតំណែងគត់ ។

បេក្ខនារី បេក្ខជន ឬបេក្ខនារីជាជនមានពិការភាព ដែលមានសមត្ថភាព និងកាយសម្បទាសមស្របទៅនឹងមុខតំណែង ត្រូវបានលើកទឹកចិត្ត ។

III- **<u>លក្ខខណ្ឌដោយឡែក</u>**

១- <u>មន្ត្រីទទួលការងារបុគ្គលិក</u> (រយៈពេលធ្វើការ ១-៤-២០១៨ ដល់ ៣១-៨-២០១៨)

- មានអាយុយ៉ាងតិច ២៣ ឆ្នាំ
- មានសញ្ញាបត្របរិញ្ញាបត្រ
- មានចំណេះដឹងខាងកុំព្យូទ័រច្បាស់លាស់ (Microsoft word and Excel)
- មានបទពិសោធន៍ខាងការងារបុគ្គលិកយ៉ាងតិច ៣ ឆ្នាំ(មានបទពិសោធន៍ការងារបុគ្គលិកនៅស្ថាប័នរដ្ឋ ប្រសិនបើមានកាន់តែប្រសើរ)
- មានចំណេះដឹងផ្នែកការងាររដ្ឋបាល និងចេះធ្វើលិខិតរដ្ឋបាលគ្រប់ប្រភេទ
- ប្រាក់កម្រៃក្នុងមួយខែទទួលបាន ២.000.000 រៀល ។

២- <u>មន្ត្រីទទួលការងារបៀវត្ស</u> (រយៈពេលធ្វើការ ១-៤-២០១៨ ដល់ ៣១-៨-២០១៨)

- មានអាយុយ៉ាងតិច ២៣ ឆ្នាំ
- មានសញ្ញាបត្របរិញ្ញាបត្រ
- មានចំណេះដឹងខាងកុំព្យូទ័រច្បាស់លាស់ (Microsoft word and Excel)
- មានបទពិសោធន៍ខាងការងារបៀវត្សយ៉ាងតិច ៣ ឆ្នាំ(មានបទពិសោធន៍ការងារបៀវត្សនៅស្ថាប័នរដ្ឋ ប្រសិនបើមានកាន់តែប្រសើរ)
- ប្រាក់កម្រៃក្នុងមួយខែទទួលបាន ២.000.000 រៀល ។

៣- <u>មន្ត្រីពិធីការ</u> (រយៈពេលធ្វើការ ១-៤-២០១៨ ដល់ ៣១-៨-២០១៨)

- មានអាយុយ៉ាងតិច ២០ ឆ្នាំ
- មានសញ្ញាបត្របរិញ្ញាបត្ររងឡើងទៅ
- មានបទពិសោធន៍ការងារពិធីការយ៉ាងតិច ២ឆ្នាំ
- មានចំណេះដឹងខាងភាសាអង់គ្លេស (អាចប្រើការបាន)
- ប្រាក់កម្រៃក្នុងមួយខែទទួលបាន ២.000.000 រៀល ។

៤- <u>មន្ត្រីបណ្ណាល័យ</u> (រយៈពេលធ្វើការ ០១-៤-២០១៨ ដល់ ៣១-៨-២០១៨)

- មានអាយុយ៉ាងតិច ២៣ ឆ្នាំ
- មានសញ្ញាបត្របរិញ្ញាបត្រ
- មានចំណេះដឹងខាងកុំព្យូទ័រច្បាស់លាស់ (Microsoft word and Excel)
- មានបទពិសោធន៍ខាងការងារបណ្ណាល័យយ៉ាងតិច១ ឆ្នាំ
  (មានបទពិសោធន៍បម្រើការងារនៅស្ថាប័នរដ្ឋផ្នែកបណ្ណាល័យ កាន់តែប្រសើរ)
- មានចំណេះដឹងខាងភាសាអង់គ្លេស (អាចប្រើការបាន)
- ប្រាក់កម្រៃក្នុងមួយខែទទួលបាន ២.000.000 រៀល ។

៥- <u>មន្ត្រីគ្រប់គ្រងទឹកភ្លើង ទូរស័ព្ទ និងឧបករណ៍បំពងសម្លេង</u> (រយៈពេលធ្វើការ ១-៤-២០១៨ ដល់ ៣១-៨-២០១៨)

- មានអាយុយ៉ាងតិច ២៣ ឆ្នាំ
- មានសញ្ញាបត្របរិញ្ញាបត្ររងផ្នែកអគ្គិសនី ឬវិញ្ញាបនបត្របញ្ជាក់ការសិក្សាផ្នែកជំនាញ
- មានបទពិសោធន៍ខាងការងារគ្រប់គ្រងទឹកភ្លើង ទូរស័ព្ទ និងឧបករណ៍បំពងសម្លេង យ៉ាងតិច២ ឆ្នាំ

- មានចំណេះដឹងខាងភាសាអង់គ្លេស (អាចប្រើការបាន)
- ប្រាក់កម្រៃក្នុងមួយខែទទួលបាន ២.000.000 រៀល ។

៦- <u>លេខាធិការ</u> (រយៈពេលធ្វើការ ១-៤-២០១៨ ដល់ ៣១-៨-២០១៨)

- មានអាយុយ៉ាងតិច ២០ ឆ្នាំ
- មានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឡើងទៅ
- មានចំណេះដឹងខាងកុំព្យូទ័រច្បាស់លាស់ (Microsoft word and Excel)
- មានបទពិសោធន៍ខាងការងារលេខាធិការយ៉ាងតិច ២ ឆ្នាំ
- ចេះសរសេររបាយការណ៍ និងធ្វើកំណត់ហេតុ
- មានចំណេះដឹងភាសាអង់គ្លេស (មធ្យម)
- ប្រាក់កម្រៃក្នុងមួយខែទទួលបាន ១.៥00.000 រៀល ។

៧- <u>លេខហារី</u> (រយៈពេលធ្វើការ ១-៤-២០១៨ ដល់ ៣១-៨-២០១៨)

- ត្រូវមានអាយុយ៉ាងតិច ១៨ឆ្នាំ
- មានបទពិសោធន៍ខាងការងារនាំសារ
- ស្គាល់ភូមិសាស្ត្រ និងមានបទពិសោធន៍ក្នុងការនាំសារ
- ចេះបើកររថយន្តកាន់តែប្រសើរ (មានប័ណ្ណបើកបរ)
- មានលទ្ធភាពធ្វើការជាក្រុម និងអាចបំពេញការងារ ៧ថ្ងៃក្នុងមួយសប្តាហ៍
- ប្រាក់កម្រៃក្នុងមួយខែទទួលបាន ១.២00.000 រៀល ។

៨- <u>អ្នកយាម (សន្តិសុខ)</u> (រយៈពេលធ្វើការ ១-៤-២០១៨ ដល់ ៣១-៨-២០១៨)

- មានអាយុយ៉ាងតិច ១៨ឆ្នាំ ឡើងទៅ
- មានអ្នកធានាទទួលស្គាល់ដែលគួរទុកចិត្តបាន
- មានបទពិសោធន៍ក្នុងការយាមល្បាតយ៉ាងតិច ២ឆ្នាំ
- ប្រាក់កម្រៃក្នុងមួយខែទទួលបាន ១.២00.000 រៀល ។

៩- <u>អ្នកសំអាត</u> (រយៈពេលធ្វើការ ១-៤-២០១៨ ដល់ ៣១-៨-២០១៨)

- មានអាយុយ៉ាងតិច ១៨ឆ្នាំ ឡើងទៅ
- មានអ្នកធានាទទួលស្គាល់ដែលគួរទុកចិត្តបាន
- មានបទពិសោធន៍ខាងការងារអនាម័យ យ៉ាងតិច ២ឆ្នាំ
- ប្រាក់កម្រៃក្នុងមួយខែទទួលបាន ១.000.000 រៀល ។

IV-**<u>ទំនាក់ទំនងព័ត៌មាន</u>**

អ្នកដែលមានបំណងដាក់ពាក្យជាបេក្ខជនតាមមុខតំណែងខាងលើនេះ សូមអញ្ជើញមកទាក់ទងដាក់ពាក្យនៅទីស្តីការ គ.ជ.ប ដែលមានទីតាំងស្ថិតនៅក្នុងក្រសួងមហាផ្ទៃ អគារ H (ខាងជើង) នៅរៀងរាល់ម៉ោងធ្វើការ ។ ពាក្យសុំចូលបម្រើការងារមានចែកជូនដោយឥតគិតថ្លៃ ។

- ចាប់ផ្តើមចែកពាក្យ និងទទួលពាក្យ ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៨ (វេលាម៉ោង ៧:00ព្រឹក)
- ឈប់ទទួលពាក្យ ថ្ងៃទី២0 ខែមីនា ឆ្នាំ២០១៨ (វេលាម៉ោង ១៧:៣0 នាទីល្ងាច)
- ការកំណត់មុខតំណែងដែលត្រូវប្រឡងសរសេរ-QCM សម្ភាសន៍ និងតេស្តកុំព្យូទ័រ ៖

+ មន្ត្រីទទួលការងារបុគ្គលិក
+ មន្ត្រីទទួលការងារបៀវត្ស
+ មន្ត្រីបណ្ណាល័យ

- ការកំណត់មុខតំណែងដែលត្រូវប្រឡងសរសេរ-QCM និងសម្ភាសន៍ ៖
  + មន្ត្រីពិធីការ
  + មន្ត្រីគ្រប់គ្រងទឹកភ្លើង ទូរស័ព្ទ និងឧបករណ៍បំពងសម្លេង
- ការកំណត់មុខតំណែងដែលត្រូវប្រឡងសរសេរ-QCM និងតេស្តកុំព្យូទ័រ ៖
  + លេខាធិការ
- ការកំណត់មុខតំណែងដែលត្រូវធ្វើសម្ភាសន៍ ៖
  + លេខហារី
  + អ្នកយាម (សន្តិសុខ)
  + អ្នកសំអាត
- បញ្ជីឈ្មោះបេក្ខជនដែលត្រូវជ្រើសរើសឱ្យចូលប្រឡងសេសរ-QCM ឬ/និងសម្ភាសន៍ ឬ/និងតេស្តកុំព្យូទ័រ នឹងបិទផ្សាយ នៅថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៨ ក្រោយពីបានធ្វើការជម្រុះជំហានទី១ ។

<u>បញ្ជាក់បន្ថែម</u> :

- សញ្ញាបត្រ ឬ/និងលិខិតបញ្ជាក់ពីបទពិសោធន៍ការងារត្រូវធ្វើនីត្យានុកូលកម្ម ឬមានការបញ្ជាក់ពីសាមីស្ថាប័ន
- គ្រប់បេក្ខជនត្រូវមានអ្នកធានាដឹងឮ យ៉ាងតិចមួយនាក់
- បេក្ខជនទាំងអស់ត្រូវធានាថា ក្រោយពីពេលដែលត្រូវបានជ្រើសរើសឱ្យចូលបម្រើការងារក្នុងមុខតំណែងណាមួយនោះត្រូវសុខចិត្តទទួលយកប្រាក់កម្រៃដូចបានកំណត់ដែលនឹងត្រូវបើកជូនក្រោយពី គ.ជ.ប បានទទួលប្រាក់ពីរតនាគារជាតិ
- មាត្រា២៤ នៃអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចែងថា ... មន្ត្រីរាជការ ដែលត្រូវបានជ្រើសរើសជាមន្ត្រីជាប់កិច្ចសន្យាបម្រើការងារឱ្យ គ.ជ.ប ត្រូវរក្សាបៀវត្ស អតីតភាពការងារសម្រាប់ការឡើងថ្នាក់ និងទទួលសោធននិវត្តន៍ នៅអង្គភាពដើមរបស់ខ្លួនដដែល ។

ថ្ងៃសៅរ៍ ៩រោច ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែមីនា ឆ្នាំ២០១៨
ជ. គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
ប្រធាន

សុិត ប៊ុនហុក